# ត្រចៀកកាំព្រាត់សំបុក

១. មេឃខ្ពស់ដីទាប ប្រៀបពុំបាន  រស់រសាត់ប្រាណ សែនឆ្ងាយស្រុក
ដីភូមិកំណើត ធ្លាប់ផ្ដល់សុខ  ឥឡូវព្រាត់ស្រុក សែនអួលអាក់។
២. ព្រាត់ដើមក្រសាំង នៅវាលស្រែ  ព្រាត់ឆ្ងាយដៃម៉ែ ធ្លាប់ថ្នមថ្នាក់
ព្រាត់ញាត្តិប្រុសស្រី ធ្លាប់រាក់ទាក់  ព្រាត់មិត្ត ខ្មែរ មហ៊្ញុក្រ រួមសាលា។
៣. ព្រាត់អាពពាល គោសំណប់  ព្រាត់ឆ្នាកំណប់ ដួងចិន្ដា
ព្រាត់គ្រូព្រះសង្ឃ ធ្លាប់ទេសនា  ព្រាត់ទានសាលា ធ្លាប់រត់លេង។
៤. ព្រាត់វត្តព្រះពុទ្ធ ធ្លាប់ធ្វើបុណ្យ  ព្រាត់បឹងសុផុន ដែលពីក្មេង
ធ្លាប់ងូតធ្លាប់ហែល ប្រលែងលេង  ឥឡូវវង្វេងចាក សែនឆ្ងាយ។
៥. ឱមាតុ កំណើត កម្ពុជា  បុរីពិលា ខ្ញុំសែនស្ដាយ
នឹកស្រណោះអ្នក មិនជិនណាយ  ទោះបីឃ្លាតកាយ ចិត្តនៅចាំ។
៦. ឱដីអង្គរ ដ៏សក្តិសិទ្ធ  សូមជួយប្រសិទ្ធ ពរម៉ឺនឆ្នាំ
អោយខ្មែរប្រុសស្រី ខ្មីចំណាំ  ចងទុកបណ្ដាំ កេរ្តិ៍ដូនតា។
៧. ឱទេពអប្សរា ព្រលឹងខ្មែរ  សូមជួយថ្នួនថែរ ជាតិខេមរា
ប្រោះព្រហ្មប្រសិទ្ធ ពរថ្លៃថ្លា  ដល់បុត្រធិតា ខ្មែរប្រុសស្រី។
៨. សូមជាតិខ្មែរខ្ញុំ បានក្ដីសុខ  រស់ផុតក្ដីទុក្ខ ទោសចង្រៃ
សូមកម្មវេរា ពៀរអប្រិយ  រលាយផុពីដី ខេមរា។
៩. សូមជនស្រីប្រុស រស់ដោយក្សាន្ត  កុំព្រាត់សណ្ដាន ញាត្តិការ
សាងសុខលើដែន ដីខេមរា  សុខសាន្តអាត្មា លុះរៀងអើយ។

**សួន សេរីរដ្ឋា**

អាមេរិក ថ្ងៃទី១៤ វិច្ឆកា ២០០៦